# អគារមជ្ឈមណ្ឌល មន្ទីរពិសោធន៍ស្តង់ដារកម្ពុជា កម្ពស់៧ជាន់ នឹងលេចរូបរាង នៅចុងឆ្នាំ២០១៩



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានរៀបចំពិធីសែនព្រេនសុំម្ចាស់ទឹកម្ចាស់ដី ដើម្បីរុះរើសំណង់អគារចាស់ នៃអតីតរោងចក្រស័ង្កសីបូព៌ា ដែលមានទីតាំង នៅតាមបណ្តោយផ្លូវជាតិលេខ២ តំបន់ចក្រអង្រែលើ ដើម្បីយកទីតាំងសម្រាប់ការសាងសង់ អគារមជ្ឈមណ្ឌលមន្ទីរពិសោធន៍ នៃស្តង់ដារកម្ពុជា កម្ពស់៧ជាន់ ដ៏ថ្មីស្រឡាងមួយ ដែលគ្រោងនឹងសាងសង់ឲ្យរួចរាល់ នៅក្នុងរយៈពេល១៨ខែ ពោលគឺនៅចុងឆ្នាំ២០១៩ ខាងមុខ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបានអញ្ជើញក្នុងពិធីនេះ បានថ្លែងឲ្យដឹងថា អគារមជ្ឈមណ្ឌលមន្ទីរ ពិសោធន៍ស្តង់ដារកម្ពុជា កម្ពស់ ៧ជាន់ ដែលនឹងត្រូវសាងសង់ លើទីតាំងនៃដីអតីតរោងចក្រស័ង្កសីបូព៌ា គឺជាសមិទ្ធិផលថ្មីមួយជាប្រវត្តិសាស្ត្រ សម្រាប់វិស័យស្តង់ដារកម្ពុជា ដែលបាននឹងកំពុងរួមចំណែកយ៉ាងសំខាន់ ក្នុងការជម្រុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។



សព្វថ្ងៃវិស័យស្តង់ដារនៅកម្ពុជា កំពុងបោះជំហានទៅមុខយ៉ាងលឿន គួរឲ្យកត់សម្គាល់ ជាក់ស្តែង គិតត្រឹមដំណាច់ឆ្នាំ២០១៧ ស្តង់ដារផលិតផលចំនួន ៨៦៨ ត្រូវបានអនុម័តដាក់ឲ្យអនុវត្ត ឆ្លើយតបយ៉ាងឆាប់រហ័ស នៅនឹងសំណូមពរប្រើប្រាស់ និងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងលើទីផ្សារ ហើយចំនួននេះមានសន្ទុះកើនឡើង រហូតដល់ទៅ២៣ដង ក្នុងរយៈពេល ៥ឆ្នាំ បើប្រៀបធៀបនឹងឆ្នាំ២០១៣ ដែលមានត្រឹមតែ ៣៨ស្តង់ដារតែប៉ុណ្ណោះ។



ជាងនេះទៅទៀត ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចាត់ទុកការពង្រឹងស្តង់ដារគុណភាពផលិតផលទំនិញ គឺជាកាតួកិច្ច និងជាការងារអាទិភាព មួយរបស់ក្រសួង ដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ចជាតិ ក្នុងពេលដែលយើងត្រូវជំនះរបាំងបច្ចេកទេស សម្រាប់គោលដៅនៃការធ្វើពិពិធកម្មទីផ្សារផលិតផល របស់យើង។

គួរបញ្ជាក់ថា អគារមជ្ឈមណ្ឌលមន្ទីរពិសោធន៍ស្តង់ដារកម្ពុជា នឹងលេចរូបរាង នាពេលខាងមុខដ៏ខ្លីនេះ គឺចំបរិបថដែលប្រទេសកម្ពុជា កំពុងបោះជំហានជាវិជ្ជមាន លើការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម ដែលនៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ វិស័យនេះបានក្លាយជាសរសរស្តម្ភមួយយ៉ាងសំខាន់ និងរឹងមាំ រួមចំណែកក្នុងកំណើតសេដ្ឋកិច្ចជាតិ បង្កើតការងារជូនប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ របស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលនឹងនាំប្រទេសកម្ពុជា ឲ្យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០។



